# របាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ ២០២២
# និងលើកទិសដៅការងារ ឆ្នាំ ២០២៣ របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍
# ក្រសួងអភិវឌ្ឍន៍ជនបទ

## ១. សេចក្តីផ្តើម

នាពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យគួរឱ្យកត់សម្គាល់ ជាមួយនឹងការរីកចម្រើននេះ ប្រជាពលរដ្ឋអាចធ្វើការផ្លាស់ទីពីកន្លែងមួយទៅកន្លែងទីកន្លែងមួយទៀត ដើម្បីការងារឬប្រកបមុខរបរផ្សេងៗ ជាពិសេសប្រជាពលរដ្ឋពេញវ័យជាច្រើននៅតាមជនបទ បានចាកចេញពីភូមិឃុំទៅធ្វើការងារនៅតាមទីប្រជុំជន និងនៅក្រៅប្រទេស ។ នៅក្នុងបរិបទបែបនេះ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបង្កើតក្រុមការងារបណ្តាញអន្តរក្រសួង ស្ថាប័ន បានផ្តួចផ្តើមដឹកនាំឱ្យមានការយកចិត្តទុកដាក់ពីជំងឺអេដស៍ ពីព្រោះបើគ្រួសារណាមានផ្ទុកជំងឺនេះ វាធ្វើឱ្យខាតបង់សេដ្ឋកិច្ច និងសុភមង្គលគ្រួសារ ប៉ះពាល់ដល់សុខភាពផ្លូវភេទ និងបាត់បង់ធនធានមនុស្ស ។ កាលថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ ក្រសួងអភិវឌ្ឍន៍ជនបទបានសម្រេចបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ មានសមាសភាពសរុប ចំនួន **១៩រូប** ស្ត្រី ចំនួន **១០រូប** និងនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រសួងបានសម្រេចកែសម្រួលសមាសភាពជាថ្មី មានសមាសភាព សរុបចំនួន **១៣រូប** ស្ត្រី ចំនួន **០៩រូប** ។ នៅឆ្នាំ ២០១៦-២០២២ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ក៏ចាប់ផ្តើមទទួលបានកញ្ចប់ថវិកាប្រើប្រាស់ក្នុងការអនុវត្តផែនការសកម្មភាពការងាររបស់ខ្លួនជាបណ្តើរៗ ទាំងនេះស្តែងចេញពីការគិតគូពីសំណាក់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទគ្រប់លំដាប់ថ្នាក់ ក្នុងការចូលរួមលើកកម្ពស់ចំណេះដឹង អំពីការងារអប់រំជំងឺឆ្លងនិងសុខភាពផ្លូវភេទរបស់ប្រជាពលរដ្ឋជនបទ ក្រុមការងារគណៈកម្មាធិការបានអនុវត្តសកម្មភាព ដោយទទួលបាននូវសមិទ្ធិផលទៅតាមផែនការដែលបានគ្រោងទុក ។

## ២. តួនាទី និងភារកិច្ច

- សិក្សាស្រាវជ្រាវក្រុមគោលដៅដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងរាលដាលមេរោគអេដស៍ និងស្វែងរកដំណោះស្រាយឱ្យបានសមស្របតាមក្រុមគោលដៅនីមួយៗ

- រៀបចំគម្រោង និងពង្រឹងសកម្មភាពបន្ត នៃកម្មវិធីអេដស៍ និង ស្វែងរកជំនួយពីគ្រប់ប្រភព ដើម្បីដំណើរការណ៍
- ចងក្រងឯកសារ និងផលិតឧបករណ៍សម្រាប់បណ្តុះបណ្តាល និងអប់រំបន្ត
- ផ្តល់ការបណ្តុះបណ្តាល និង ការកសាងសមត្ថភាពផ្សេងៗ ដល់សមាជិកគណៈកម្មការ និង ក្រុមការងារដែលជាជំនួយឱ្យគណៈកម្មការ និងក្រុមគោលដៅ
- ផ្តល់ការប្រឹក្សាយោបល់ផ្សេងៗដល់ក្រុមប្រឈមមុខនឹងគ្រោះថ្នាក់ និងជនងាយរងគ្រោះ នៅតាមតំបន់ជនបទ
- ទំនាក់ទំនង និងសម្របសម្រួលជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៏បណ្តារក្រសួងពាក់ព័ន្ធនិងអង្គការនានា ក្នុងការស្វែងរកកិច្ចសហការនិងការគាំទ្រដល់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងអភិវឌ្ឍន៍ជនបទ
- ជំរុញ និងបង្កើតឱ្យមានបណ្តាញនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទខេត្តនីមួយៗ ដើម្បីផ្សព្វផ្សាយ និងអប់រំផ្ទាល់ដល់សហគមន៍ អំពីការទប់ស្កាត់ និងបង្ការការរីករាលដាលមេរោគ ជំងឺអេដស៍
- តាមដាន និងវាយតំលៃលទ្ធផលការងារ។

## ៣. សមិទ្ធផលសម្រេចបាន

- រៀបចំប្រជុំផ្ទៃក្នុងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ចំនួន ០៣ លើក
- រៀបចំបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី លើកកម្ពស់ការយល់ដឹងពីជំងឺអេដស៍ កាមរោគ សុខភាពបន្តពូជ និងគ្រឿងញៀន ដល់ប្រជាពលរដ្ឋនៅសហគមន៍ជនបទ ចំនួន ០១ លើក នៅខេត្តបាត់ដំបង មានអ្នកចូលរួមសរុប ចំនួន **៩២នាក់** ស្ត្រី ចំនួន **៥១នាក់**
- ចុះត្រួតពិនិត្យនិងតាមដានការងារបានចំនួន**៣ខេត្ត** គឺខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តកំពង់ស្ពឺ
- ចូលរួមកិច្ចប្រជុំក្រុមបច្ចេកទេស នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន **១១ លើក**
- ចូលរួមប្រជុំ អំពី ការធ្វើផែនការថវិកា ចំនួន **០២ លើក** តាមប្រព័ន្ធ Online
- ចូលរួមសន្និបាតបូកសរុបជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន **០១ លើក** នៅខេត្តព្រះសីហនុ
- ចូលរួមទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ចំនួន **០១ លើក** នៅសាលចតុមុខភ្នំពេញ

## ៤. បញ្ហាប្រឈម

- ថវិកាសម្រាប់អនុវត្តការងារនៅមានកម្រិតទាប
- បញ្ហា កូវីដ-១៩ ក្រសួងហិរវត្ថុកាត់កញ្ចប់ថវិកាសម្រាប់អនុវត្តការងារ
- ខ្វះការសហការរវាងគម្រោងឬដៃគូអភិវឌ្ឍន៍នានាជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ។

## ៥. សំណូមពរ

- បង្កើនកញ្ចប់ថវិកាជាតិសម្រាប់អនុវត្តការងារអេដស៍
- មានកិច្ចសហការនិងគាំទ្រធនធានថវិការវាងគម្រោងឬដៃគូអភិវឌ្ឍន៍នានារបស់ក្រសួង
- បង្កើនការគាំទ្រពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់

## ៦. ផែនការ និងទិសដៅ

- រៀបចំបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយ នៅភូមិឃុំខេត្តគោលដៅ
- ចុះត្រួតពិនិត្យ និងតាមដានការងារ នៅភូមិឃុំខេត្តគោលដៅ
- មានកិច្ចសហការល្អ ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## ៧. សេចក្តីសន្និដ្ឋាន

នៅក្នុង ២០២៣ នេះ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងអភិវឌ្ឍន៍ជនបទ នឹងប្តេជ្ញាចិត្តខិតខំអនុវត្តនូវតួនាទី របស់ខ្លួនក្នុងការអនុវត្តសកម្មភាពការងារទៅតាមផែនការថវិកា និងផែនការយុទ្ធសាស្រ្ត ដើម្បីទទួលបាននូវលទ្ធផលគួរជាទីមោទនៈក្នុងការលើកកម្ពស់ និងផ្តោតកម្មវិធីអប់រំផ្សព្វផ្សាយចំពោះប្រជាពលរដ្ឋដែលមានសក្តានុពលប្រឈមមុខខ្ពស់ទៅនឹងគ្រោះថ្នាក់ នៃការចម្លងមេរោគអេដស៍ ជំងឺអេដស៍និងសុខភាពផ្លូវភេទ ជាពិសេសយុវវ័យដែលត្រៀមនឹងធ្វើចំណាកស្រុក ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកប្រើគ្រឿងញៀន ទាំងនេះជាផ្នែកមួយ នៃការចូលរួមចំណែកក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្នុងការរួមចំណែកសម្រេចទស្សនវិស័យគោលដៅយុទ្ធសាស្រ្តជាតិ **៩៥ ៩៥ ៩៥** នៅ **ឆ្នាំ**២០២៥ ៖ ១). គ្មានការចម្លងមេរោគអេដស៍ថ្មី ២). គ្មានការរើសអើងលើអ្នកផ្ទុកមេរោគអេដស៍ ៣). និងគ្មានការស្លាប់ដោយសារជម្ងឺអេដស៍ សំដៅចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សុខភាពផ្លូវភេទរបស់ប្រជាពលរដ្ឋតាមរយៈវិស័យអភិវឌ្ឍន៍ជនបទ។